# រោងចក្រអ៊ឹមនិងវ៉េ កាត់ដេរអន្តរជាតិមានកំរិត

澳越国际有限公司

**M&V INTERNATIONAL MANUFACTURING LTD.**

អាស័យដ្ឋាន:ផ្លូវជាតិលេខ៥ ភូមិត្រពាំងចឹកសា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។

Address:5#road, TropengCheksa Village, Kampong Chhnang Commune, Kampong Chhnang City, Kampong Chhnang Province.

## កិច្ចព្រមព្រៀងស្នើសុំព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២៣ វេលាម៉ោង០៩និង៣០នាទីព្រឹកនៅក្នុងរោងចក្រ អ៊ឹមនិង វ៉េ កាត់ដេរអន្តរជាតិ អិលធីឌី មានកិច្ចប្រជុំរវាងតំណាងក្រុមហ៊ុន ប្រតិភូបុគ្គលិក និងតំណាងសហជីពមូលដ្ឋាន។

ក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុនខ្វះការបញ្ជាទិញពីអតិថិជន។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៨១០នាក់ (ស្រី១២១៩នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន២៦៨៤នាក់ (ស្រី២១៥៧នាក់) រយៈពេល៦០ថ្ងៃ គិតចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤ ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤។ ហើយក្នុងកំឡុងពេលព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតម្នាក់ ចំនួន៩០ដុល្លា ក្នុងនោះ៖

-ចំនួន៣០ដុល្លា ពីថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០២៤ ដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២៤

-ចំនួន៣០ដុល្លា ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២៤ ដល់ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ២០២៤

-ចំនួន៣០ដុល្លា ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០២៤ ដល់ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២៤

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនឹងបើកជូនបងប្អូនកម្មករនៅថ្ងៃទី ១០នៃខែបន្ទាប់។

អង្គប្រជុំបានចប់នៅវេលាម៉ោង១០និង៣០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងល្អ។

ថ្ងៃសុក្រ ២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

ធ្វើនៅកំពង់ឆ្នាំង ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣

តំណាងក្រុមហ៊ុន

អ៊ឹម វ៉េ កាត់
ដេរអន្តរជាតិ លីមីធីត
M&V INTERNATIONAL MANUFACTURING LTD

